ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ ១៣២ ប្រ.ក

ភ្នំពេញ. ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០០៧

# ប្រ កា ស

## ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធ របស់នាយកដ្ឋាន ផែនការ ស្ថិតិ និងសរុប

## រដ្ឋមន្ត្រីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល កម្ពុជានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២ ន.ស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ២៤ អនុក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប

## ស ម្រេ ច

**ប្រការ១** : នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ស្ថិត ក្រោមឱវាទអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានសមត្ថកិច្ចកសាងផែនការ ស្ថិតិ និងសរុប ។

**ប្រការ២** : នាយកដ្ឋានផែនការ ស្ថិតិ និងសរុប មានភារកិច្ចដូចតទៅ ÷

១.ធ្វើឱ្យសម្រេច និងផ្សព្វផ្សាយនូវការងារសិក្សាស្រាវជ្រាវ និងបូកសរុប ដែលពាក់ព័ន្ធ និងវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ចនៃវិស័យវប្បធម៌ ព្រមទាំងផ្ទៀងផ្ទាត់ការប្រើប្រាស់បានល្អនូវបណ្តលទ្ធផលទាំងនេះ ។

២.វិភាគ និងកសាងផែនការអភិវឌ្ឍន៍វិស័យវប្បធម៌ រយៈពេលខ្លី មធ្យម និងវែង និងតាមដានការអនុវត្តនោះ ។

៣.រៀបចំ កសាងគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យវប្បធម៌ និងកំណត់គោលដៅនៃការអភិវឌ្ឍនោះ ។

៤.សិក្សាពិចារណាលើវិធីសាស្ត្រធ្វើការងារក្នុងក្រសួង ព្រមទាំងលើកសំណើផ្សេងៗ ដើម្បីកែសម្រួល ។

៥.រៀបចំកសាងកម្មវិធីវិនិយោគសាធារណៈ និងរៀបចំតម្រង់ទិសកម្មវិធីវិនិយោគឯកជនក្នុងវិស័យវប្បធម៌។

៦.រៀបចំ គម្រោងផែនការអំពីតម្រូវការចាំបាច់នានារបស់ក្រសួង ដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ និងសុំជំនួយឧបត្ថម្ភផ្សេងៗ ។

៧.សហការជាមួយក្រសួងផែនការ ដើម្បីរៀបចំប្រព័ន្ធស្ថិតិមួយ អំពីជីវភាពវប្បធម៌ទូទាំងប្រទេស ។

៨.រៀបចំ ចងក្រងកម្មវិធីវប្បធម៌ សម្រាប់ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍ ។

**ប្រការ៣** : នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង អនុប្រធាន មួយចំនួនជាជំនួយការ។

**ប្រការ៤** : នាយកដ្ឋានផែនការ ស្ថិតិ និងសរុប មានការិយាល័យ៦ គឺ ÷

១.ការិយាល័យ រដ្ឋបាល

២.ការិយាល័យ ផែនការ

៣.ការិយាល័យ ស្ថិតិវប្បធម៌

៤.ការិយាល័យ រៀបចំវិធីសាស្ត្រការងារ

៥.ការិយាល័យ ផែនការវិនិយោគសាធារណៈ

៦.ការិយាល័យ សរុប និងលើកគំរោងផែនការសកម្មភាពការងារ

ការិយាល័យនីមួយៗ មានប្រធានមួយរូបទទួលខុសត្រូវរួម និងមានអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គការលេខ របស់នាយកដ្ឋានផែនការ ស្ថិតិ និងសរុប នៃប្រកាសនេះ។

**ប្រការ៥** : ភារកិច្ចការិយាល័យនីមួយៗមាន ÷

**១.ការិយាល័យ រដ្ឋបាល :**

-គ្រប់គ្រងការងាររដ្ឋបាល

-គ្រប់គ្រងការងារ បុគ្គលិក និងកិច្ចការសង្គម

-គ្រប់គ្រងការងារគណនេយ្យ សំភារៈបរិក្ខារ។

**២.ការិយាល័យផែនការ :**

-កសាងផែនការអភិវឌ្ឍន៍វិស័យវប្បធម៌ រយៈពេលខ្លីមធ្យម និងវែង នឹងតាមដានការអនុវត្តនោះ

-រៀបចំកសាងគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យវប្បធម៌ និងកំណត់គោលដៅទីតាំង នៃការអភិឌ្ឍន៍នោះ

**៣.ការិយាល័យ ស្ថិតិវប្បធម៌**

-សិក្សាស្រាវជ្រាវជីវភាពវប្បធម៌ ពីចំណូលចិត្ត ករិតយល់ដឹងវប្បធម៌របស់ប្រជាជនទូទាំងប្រទេស។

-ធ្វើប្រព័ន្ធស្ថិតិ ជីវភាពវប្បធម៌ទូទាំងប្រទេស។

**៤.ការិយាល័យ រៀបចំវិធីសាស្រ្តការងារ :**

-សិក្សាពិចារណា លើវិធីសាស្រ្តធ្វើការងារ

-រកអាទិភាព នៃវិធីសាស្រ្តការងារ

-ធ្វើតុល្យការ និងវាយតំលៃរាល់សកម្មភាព និងលទ្ធផលការងាររបស់ក្រសួង

-សិក្សាស្រាវជ្រាវបូកសរុប តាមបែបបទវិទ្យាសាស្រ្តសង្គម និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

-ចងក្រងកម្មវិធីសម្រាប់ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍។

**៥.ការិយាល័យ ផែនការវិនិយោគសាធារណៈ :**

ទំនាក់ទំនងផ្នែកជំនាញជាមួយក្រសួងផែនការ ផ្នែកវិនិយោគសាធារណៈ PIP និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) :

-ជាខ្សែបណ្តាយជាមួយក្រសួងផែនការ **លើកគំរោងវិនិយោគសាធារណៈ**ទៅតាមគោលនយោបាយរបស់ក្រសួងក្នុងការរៀបចំផែនការ និងកម្មវិធីសំរាប់កិច្ចអភិវឌ្ឍន៍រយៈពេល វែង មធ្យម និងរយៈពេលខ្លី ដោយសំរបសំរួលជាមួយនាយកដ្ឋាននានាជុំវិញក្រសួង និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង។

-លើកគំរោងផែនការប្រចាំឆ្នាំ និងយូរអង្វែង តាមទិសដៅរបស់ក្រសួង ដើម្បីស្នើសុំថវិកាទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) នូវគំរោងសាងសង់ជួសជុល និងបំពាក់ទុព្វសំភារៈ ក្នុងក្របខ័ណ្ឌជំនួយ និងតាមដានការអនុវត្តគំរោង និងកម្មវិធីវិនិយោគសាធារណៈនូវជំនួយទាំងនោះ។

-ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស ឆ្នាំ ចំពោះគំរោងសាងសង់ជួសជុល និងបំពាក់សំភារៈទាំងក្របខ័ណ្ឌជំនួយ និងថវិកាផ្តល់ប្រចាំឆ្នាំ។

-តាមដាន ត្រួតពិនិត្យការអនុវត្តផែនការសាងសង់ និងជួសជុលសំណង់ជុំវិញក្រសួង និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង ដោយសហការជាមួយនាយកដ្ឋានសំភារៈ និងបរិក្ខារ ដើម្បីជំរុញអោយការដ្ឋានសំណង់នីមួយៗមានលទ្ធផលល្អប្រសើរ។

**៦.ការិយាល័យសរុប និងគំរោងផែនការសកម្មភាព :**

-ធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារវិស័យវប្បធម៌ និងលើកឡើងនូវគំរោងផែនការសកម្មភាពការងារជារួមរបស់ក្រសួងប្រចាំ ខែ ត្រីមាស ឆមាស នព្វន្តមាស និងឆ្នាំ។

-រៀបចំគម្រោងផែនការ អំពីតម្រូវការចាំបាច់នានារបស់ក្រសួង ដើម្បីបញ្ចូលទៅក្នុងគម្រោងថវិការដ្ឋសំរាប់គ្រប់គ្រងប្រចាំឆ្នាំ និងសុំជំនួយឧត្តម្ភផ្សេងៗ។

**ប្រការ៦** : នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ជាអង្គភាពអនុវត្តរបបហិរញ្ញវត្ថុរដ្ឋបាលសាធារណៈ។

**ប្រការ៧** : នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកសទេសវប្បធម៌ អគ្គនាយក នៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សកលវិទ្យាធិការ នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប និងអង្គភាពពាក់ព័ន្ធទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

**ចំលងជូន**

- ទីស្តីការគណៈមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
  "ដើម្បីជ្រាបជាព័តិមាន"
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខ នាយកដ្ឋានផែនការ ស្ថិតិ និងសរុប




- ប្រធាន = ១ នាក់
- អនុប្រធាន = ៤ នាក់
- ថ្នាក់ការិយាល័យ = ១៨ នាក់
- មន្ត្រី = ១៤ នាក់

សរុប = ៣៧ នាក់